# ប៊ីណូ, ប៊ូប៊ិយ, និងបានតាយ ជាមិត្ត ល្អនឹងគ្នា




រៀបរៀងដោយ៖

Josephine V. Sabile

Maria Cecille R. Arca

រូបភាពដោយ៖

Reynalyn Doringo



Developed by:

Global Alliance for Rabies Control

Reproduced for:

# សម្រាប់គ្រូបង្រៀន ឬឪពុកម្ដាយ៖

រឿងនិទាន របស់ ប៊ីណូ, ប៊ូប៊យ និង បានតាយ ដែលជាមិត្តល្អនឹងគ្នា ត្រូវបានសរសេរឡើងសម្រាប់បង្រៀនកុមារពីការថែទាំនិងគ្រប់គ្រងសត្វឆ្កែឬឆ្មាឱ្យបានត្រឹមត្រូវ ដើម្បីបង្ការកុំឱ្យពួកវាខាំ។ រឿងនិទាននេះ ក៏មានគោលបំណងបង្រៀនកុមារឱ្យបានយល់ដឹងពីសារៈសំខាន់នៃការជូនដំណឹងដល់មនុស្សធំប្រសិនបើពួកគេត្រូវបានឆ្កែឬឆ្មាខាំ ដើម្បីទទួលបានការថែទាំវេជ្ជសាស្ត្រទាន់ពេលវេលានិងបង្ការជំងឺឆ្កែឆ្កួតផងដែរ។

ជំងឺឆ្កែឆ្កួតគឺជាជំងឺដែលបណ្ដាលឱ្យមនុស្សស្លាប់ហើយបង្ករឡើងដោយវីរុស។ ជាទូទៅជំងឺឆ្កែឆ្កួតឆ្លងពីសត្វទៅមនុស្សតាមរយៈការខាំដោយសត្វឆ្កែឬសត្វឆ្មា ដែលមានផ្ទុកជំងឺឆ្កែឆ្កួត។ របៀបចម្លងផ្សេងទៀតគឺតាមរយៈទឹកមាត់ដែលមានផ្ទុកជំងឺឆ្កែឆ្កួតចូលទៅក្នុងរបួសថ្មីៗ កន្លែងដាច់រលាត់ និងផ្នែកផ្សេងៗទៀតនៃរាងកាយដែលមានភ្នាសរំអិលដូចជា ច្រមុះ ភ្នែក និងមាត់។

កុមារមានហានិភ័យខ្ពស់ជាងគេ ជាពិសេសដោយសារតែមាឌនិងសកម្មភាពរបស់ពួកគេ។ ជំងឺឆ្កែឆ្កួតមិនអាចព្យាបាលបានទេ ប៉ុន្តែអាចបង្ការវាបាន 100% ដោយការចាក់វ៉ាក់សាំងសត្វឆ្កែនិងសត្វឆ្មាប្រឆាំងនឹងជំងឺឆ្កែឆ្កួតចាប់ពីអាយុបីខែឡើង និងត្រូវចាក់រៀងរាល់១ឆ្នាំម្តង។

ប្រសិនបើសត្វឆ្កែឬសត្វឆ្មាខាំ អ្នកត្រូវតែធ្វើតាមការណែនាំខាងក្រោមនេះ៖

១. លាងរបួសភ្លាមៗជាមួយសាប៊ូ និងទឹកលំហូរយ៉ាងតិចរយៈពេល១៥នាទី។

២. លាងសម្អាតជាមួយថ្នាំរម្ងាប់មេរោគ (Iodine) ឬអាល់កុលប្រសិនបើមាន។

៣. ប្រញាប់ទៅជួបគ្រូពេទ្យ ឬគ្លីនិកដែលមានទីតាំងនៅជិតបំផុត។

# ប៊ីណូ, ប៊ូប៊យ និង បានតាយ គឺជាមិត្តល្អនឹងគ្នា

រៀបរៀងដោយ៖
Josephine V. Sabile
Maria Cecille R. Arca

រូបភាពដោយ៖
Reynalyn Doringo



ថ្ងៃមួយ ម្ដាយឪពុករបស់ប៊ីណូ រៀបចំ
ព្រឹត្តិការណ៍ដ៏ភ្ញាក់ផ្អើលអស្ចារ្យមួយសម្រាប់គេ។

ប៊ីណូ និយាយថា «វ៉ាវ, កូនឆ្កែដ៏ស្រស់ស្អាតមួយ!
ខ្ញុំនឹងដាក់ឈ្មោះវាថា បានតាយ។ អរគុណប៉ា
ម៉ាក់»។



ប៊ីណូ ស្រឡាញ់ បានតាយ ខ្លាំងណាស់។ គេ
ផ្តល់ចំណី ហើយលេងជាមួយវាជារៀងរាល់
ថ្ងៃ។



នៅព្រឹកថ្ងៃសៅរ៍ ប៊ីណូ សុំអនុញ្ញាតពីម្ដាយរបស់គេដើម្បីយក បានតាយ ទៅលេងនៅកន្លែងក្មេងលេង។

ម្ដាយបានឆ្លើយនិងណែនាំថា «ចាស បាន ប៊ីណូ, កូនអាចយក បានតាយ ទៅបាន តែត្រូវប្រាកដថា កូនមិនធ្វើឱ្យវាវង្វេង ឬបាត់ឡើយ»។



ប៊ីណូ លេងយ៉ាងសប្បាយរីករាយជាមួយ
បានតាយ និងមិត្តភក្តិម្នាក់ទៀតឈ្មោះ
ប៊ូប៊ិយ។



បន្ទាប់ពីលេងរួច ប៊ីណូនិងប៊ូប៊ិយ បានផ្ដល់អាហារដល់ បានតាយ។ ខណៈពេលដែល បានតាយ កំពុងស៊ីចំណី ស្រាប់តែភ្លាមៗនោះ ប៊ូប៊ិយ ចាប់លើក បានតាយ ឡើង។

«អូយ! បានតាយ ខាំខ្ញុំ» ប៊ូប៊ិយ លាន់មាត់។



អ្នកទាំង៣ប្រញាប់ប្រញាល់ទៅផ្ទះរបស់ ប៊ូប៊ិយ។

ពួកគេបានប្រាប់ម៉ាក់របស់ ប៊ូប៊ិយ អំពីការខាំនោះ។

ម្តាយរបស់ ប៊ូប៊ិយ បានលាងរបួសភ្លាមៗជាមួយសាប៊ូ និងទឹកលំហូររយៈពេល១៥នាទី។

គាត់និយាយថា «ពួកយើងត្រូវតែទៅ គ្លីនិក ដើម្បីជួបជាមួយគ្រូពេទ្យ»។



នៅគ្លីនិក.....

ប៊ូប៊ិយ ត្រូវបានចាក់វ៉ាក់សាំងបង្ការជំងឺឆ្កែឆ្កួត។

គ្រូពេទ្យបាននិយាយថា «កូនៗ ធ្វើបានល្អដែល
បានប្រាប់ម្ដាយភ្លាមៗថា ប៊ូប៊ិយ
ត្រូវបានឆ្កែខាំ»។

«វាជារឿងល្អផងដែរ ដែលម្ដាយប៊ូប៊ិយបានលាងមុខរបួសជាមួយសាប៊ូនិងទឹកស្អាត ហើយបាននាំគេមកទីនេះភ្លាមៗ ដើម្បីចាក់វ៉ាក់សាំងបង្ការជំងឺឆ្កែឆ្កួត»។ គ្រូពេទ្យបានបន្ថែមទៀតថា «កុំភ្លេចនាំប៊ូប៊ិយ មកចាក់វ៉ាក់សាំងបន្ថែមទៀត ដើម្បីបង្ការឱ្យបានពេញលេញ កុំឱ្យគេកើតជំងឺឆ្កែឆ្កួត»។



គ្រូពេទ្យបានរំលឹកថា «ជានិច្ចកាលត្រូវចាំថា, យើងត្រូវតែថែទាំសត្វចិញ្ចឹមរបស់យើងឱ្យបានល្អ ដោយផ្តល់អាហារល្អៗ នាំធ្វើលំហាត់ប្រាណ និងបង្កភាពស្និទ្ធស្នាលជាមួយពួកវា។ កុំរំខានសត្វដែលកំពុងដេក ឬកំពុងស៊ីចំណីព្រោះយើងអាចធ្វើឱ្យវាខាំ»។

គ្រូពេទ្យបន្ថែមទៀតថា «ប្រសិនបើសត្វឆ្កែខាំអ្នកៗត្រូវសង្កេតតាមដានសត្វឆ្កែនោះក្នុងរយៈពេល១៤ថ្ងៃ និងពិភាក្សាជាមួយពេទ្យសត្វ»។



តាំងពីពេលនោះមក ពួកគេមិនដែលរំខាន
បានតាយ នៅពេលកំពុងស៊ីចំណីនិងកំពុង
ដេកឡើយ។

បឺណូនិងប៊ូប៊យបានក្លាយជាមិត្តភក្តិដ៏ល្អ និងមានការ
ទទួលខុសត្រូវចំពោះ បានតាយ។

បឺណូ ចាត់ទុក បានតាយ ជាមិត្តដ៏ល្អរបស់គេផងដែរ។

# អំពីអ្នកនិពន្ធ៖

Josephine V. Sabile គឺជាគ្រូបង្រៀនមកពីសាលាបឋមសិក្សា Labas ក្នុងទីក្រុង Santa Rosa នៃរដ្ឋ Laguna ។ អ្នកគ្រូទទួលបានពានរង្វាន់គ្រូបង្រៀនឆ្នើមក្នុងឆ្នាំ២០១២ ពីមន្ទីរអប់រំនៃទីក្រុង Santa Rosa។ គាត់បានបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកអប់រំកម្រិតបឋមពីសាកលវិទ្យាល័យ Adamson ។ គាត់ក៏បានសិក្សាមុខវិជ្ជាជាច្រើនទៀតសម្រាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកសិល្បៈនៃការបង្រៀនភាសាអង់គ្លេស មកពីសាកលវិទ្យាល័យ Normal នៃប្រទេសហ្វីលីពីន។ គាត់បានរៀបការជាមួយ Joel និងមានកូនពីរនាក់។

Maria Cecille R. Arca គឺជាគ្រូបង្រៀនថ្នាក់មត្តេយ្យមកពីសាលាបឋមសិក្សា Labas ក្នុងទីក្រុង Santa Rosa នៃរដ្ឋ Laguna ។ អ្នកគ្រូបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ Southern Luzon State University, Lucban Quezon ថ្នាក់បរិញ្ញាបត្រផ្នែកអប់រំកម្រិតបឋមជំនាញផ្នែកអប់រំកុមារតូចក្នុងឆ្នាំ២០០៧ ។

# ១០ចំណុចសំខាន់ៗ ដែលអ្នកគួរយល់ដឹងអំពីជំងឺឆ្កែឆ្កួត៖

១. សូមយកសត្វឆ្កែនិងឆ្មារបស់អ្នកទៅចាក់វ៉ាក់សាំងបង្ការជំងឺឆ្កែឆ្កួតជារៀងរាល់ឆ្នាំ។

២. សូមថែទាំសត្វចិញ្ចឹមរបស់អ្នកឱ្យបានល្អ។ ផ្តល់អាហារដល់សត្វចិញ្ចឹមឱ្យបានគ្រប់គ្រាន់ នាំធ្វើលំហាត់ប្រាណ បង្កភាពស្និទ្ធស្នាល និងឱ្យពួកវាស្នាក់នៅកន្លែងដែលមានសុវត្ថិភាព។

៣. សូមកុំឱ្យសត្វឆ្កែនិងឆ្មារបស់អ្នក ដើរដោយសេរីលើដងផ្លូវនិងទីសាធារណៈ។

៤. សូមកុំធ្វើបាបសត្វឆ្កែនិងសត្វឆ្មា។ កុំទាត់ កុំទាញកន្ទុយ ឬមួយគប់ដុំថ្មដាក់ពួកវា។

៥. សូមនៅឱ្យឆ្ងាយពីសត្វឆ្កែឬឆ្មាអនាថា។ កុំរំខានសត្វឆ្កែនិងសត្វឆ្មារបស់អ្នកនៅពេលកំពុងដេក កំពុងស៊ីចំណី និងបំបៅដោះកូនៗរបស់ពួកវា។

៦. ប្រសិនបើសត្វឆ្កែឬឆ្មាខាំ អ្នកត្រូវលាងរបួសភ្លាមៗជាមួយសាប៊ូនិងទឹកលំហូរ។

៧. សូមប្រាប់មនុស្សចាស់ (ដូចជាឪពុកម្តាយ គ្រូបង្រៀន ឬអាណាព្យាបាល) ភ្លាមៗប្រសិនបើត្រូវឆ្កែឬឆ្មាខាំ ហើយសុំឱ្យពួកគេនាំអ្នកទៅគ្លីនិកឬទៅជួបគ្រូពេទ្យ។

៨. សូមចងចាំថាមនុស្សអាចឆ្លងជំងឺឆ្កែឆ្កួតតាមរយៈទឹកមាត់ (ពីការខាំឬខ្វាច) របស់សត្វឆ្កែឬឆ្មាដែលមានផ្ទុកជំងឺឆ្កែឆ្កួត។

៩. ជំងឺឆ្កែឆ្កួតអាចសម្លាប់អ្នកបាន។

១០. ជំងឺឆ្កែឆ្កួតអាចបង្ការបាន ដោយយកសត្វឆ្កែនិងឆ្មារបស់អ្នកទៅចាក់វ៉ាក់សាំងបង្ការជំងឺឆ្កែឆ្កួត។

# គម្រោងអន្តរាគមន៍សម្រាប់កុមារតូច

ជាទូទៅកុមារតែងត្រូវឆ្កែនិងឆ្មាខាំ។ ដោយសារតែហេតុផលនេះ សម្ព័ន្ធសកលសម្រាប់ការគ្រប់គ្រងជំងឺឆ្កែឆ្កួត (GARC) បានផ្តួចផ្តើមកម្មវិធីអន្តរាគមន៍សម្រាប់កុមារតូច ឬហៅកាត់ថា ECI ឡើង។

ECI មានគោលបំណងអប់រំកុមារដែលមានអាយុចាប់ពី៣ទៅ៥ឆ្នាំនៅតាមមជ្ឈមណ្ឌលថែទាំកុមារ អំពីរបៀបថែទាំនិងគ្រប់គ្រងសត្វចិញ្ចឹមឱ្យបានត្រឹមត្រូវដើម្បីបង្ការការខាំ។ ដូចគ្នានេះផងដែរ ECI ក៏មានគោលបំណងបង្រៀនកុមារឱ្យចេះផ្តល់ដំណឹងដល់មនុស្សចាស់ដូចជាឪពុកម្តាយ ឬមនុស្សធំផ្សេងទៀត ប្រសិនបើពួកគេត្រូវសត្វឆ្កែឬឆ្មាខាំឬខ្វាច។ ឪពុកម្តាយរបស់កុមារតាមមជ្ឈមណ្ឌលទាំងនោះ ក៏ទទួលបានការអប់រំអំពីជំងឺឆ្កែឆ្កួត ភាពជាម្ចាស់លើសត្វចិញ្ចឹមប្រកបដោយការទទួលខុសត្រូវ និងការគ្រប់គ្រងករណីមានសត្វខាំផងដែរ។

រឿងនិទាន «ស៊ី ប៊ីណូ, ស៊ី ប៊ូប៊យ, ស៊ី បានតាយ, Magkaibigang Tunay (ប៊ីណូ, ប៊ូប៊យ, and បានតាយ ជាមិត្តល្អនឹងគ្នា)» ត្រូវបានសរសេរដោយ Josephine Sabile និង Maria Cecille Arca ដោយរួមសហការជាមួយមន្ទីរអប់រំនៃទីក្រុង Sta. Rosa ដែលជាផ្នែកមួយនៃកម្មវិធី ECI ។

GARC គឺជាអង្គការមិនរកប្រាក់ចំណេញមួយធ្វើការដើម្បីលុបបំបាត់ការស្លាប់ដោយជំងឺឆ្កែឆ្កួត ដែលបណ្តាលមកពីសត្វឆ្កែឬឆ្មា នៅត្រឹមឆ្នាំ២០៣០។ សៀវភៅនេះត្រូវបានបោះពុម្ពដោយអង្គការ GARC ក្នុងភាពជាដៃគូជាមួយ UBS Optimus Foundation ដើម្បីបង្កើនការយល់ដឹងនៅតាមសហគមន៍ដើម្បីបង្ការការស្លាប់ដោយជំងឺឆ្កែឆ្កួត។

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រអង្គការ GARC
website: www.rabiesalliance.org

ALL RIGHTS RESERVED. This material is for educational purposes only. No reproduction of this storybook shall be used for commercial purposes. Proper citation should be observed when using this material.